# ការសំភាសន៍ជាលើកទី២របស់អ្នកមីង សាន សុដា

កៈ អ្នកដែលសំភាសន៍ឈ្មោះ ញ៉ែម សុគន្ធា ខៈ អ្នកដែលត្រូវគេសំភាសន៍ សាន សុដា

## ការសង្ខេបលើកទី២របស់អ្នកមីង សាន សុដា

នៅក្នុងការសំភាសន៍ការសំភាសន៍ជាលើកទី២អ្នកមីងសាន សុដា គាត់បានប្រាប់ពីប្រវត្តិរបស់គាត់នៅពេលដែលស្វាមីគាត់បានធ្វើបាបចិត្តគាត់ គឺស្វាមីគាត់ដើរមានប្រពន្ធចុងយ៉ាងច្រើនអស់ពីមួយទៅមួយធ្វើអោយគាត់លំបាកចិត្ត តែមកដល់ឥឡូវគាត់លែងទទួលយកប្តីគាត់ទៀតហើយព្រោះប្តីគាត់គិតថាកុហក បោកប្រាស់គាត់រហូត។អ្នកមីងបានកើតទាន់របបសង្គ្រាមតែគាត់នៅតូចគាត់បានចាំសាច់រឿងខ្លះៗ ហើយគាត់បានប្រាប់ថា គាត់បានឃើញគេសម្លាប់មនុស្សរះពោះ គឺគួរអោយរន្ធត់ណាស់ ។នៅក្នុងភូមិអ្នកមីងពុំសូវមានមនុស្សស្លាប់ច្រើនប៉ុន្មានទេហើយការហូបចុកក៏មានភាពងាយស្រួលពីកន្លែងផ្សេង នេះគឺជាសំណាងមួយរបស់ពួកអ្នកភូមិនឹងគាត់។

កៈ

ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកមីងដើម្បីអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងជាលើកទី២នាងខ្ញុំឈ្មោះញ៉ែម សុគន្ធាជាអ្នកសំភាសន៍នៅក្នុងថ្ងៃនេះហើយថ្ងៃដែលពួកយើងសំភាសន៍គឺនៅក្នុងខែមករា ឆ្នាំ២០១៨ ការសំភាសន៍នេះគឺមានទីតាំងនៅក្នុងភូមិលេខ៥ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជាហើយនាងខ្ញុំឈ្មោះញ៉ែម សុគន្ធាជាសំភាសន៍អ៊ីចឹងដោយសារពេលមុនពួកយើងអត់ទាន់បានសួរសំនួរខ្លះបន្ថែមទៀតអំពីជីវប្រវត្តិអ្នកមីងអោយបានក្បោះក្បាយ អ៊ីចឹងក៏មានការសំភាសន៍ជាលើកទី២ដើម្បីអោយអ្នកមីងបាននិយាយអ្វីចេញពីដួងចិត្តរបស់អ្នកមីងក៏ដូចជាពួកយើងមានសំនួរខ្លះៗផងដែរ អ៊ីចឹងអ្នកមីងសូមប្រាប់ឈ្មោះពេញរបស់អ្នកមីងម្តងទៀតហាំ!!

ខៈខ្ញុំឈ្មោះ សាន សុដា។

ក៖ចាំ!!ហ្នឹងហើយឥឡូវអ្នកមីងអាយុ៥០ឆ្នាំហើយ
ចាំអ៊ីចឹងអ្នកមីងសំរាប់ស្វាមីអ្នកមីងគាត់ឈ្មោះអីគេដែរ?

ខ៖ស្វាយ ខុន។

ក៖ស្វាយខុន!!អ៊ីចឹងគាត់អាយុប៉ុន្មានហើយឥឡូវ?

ខ៖មិនដឹងប៉ុន្មានទេ ៩០គត់មិនដឹងទេ!!ឆ្នាំប៉ុន្មានមិនដឹងកើតឆ្នាំប៉ុន្មានផង។

ក៖ប្អូនអ្នកមីងប៉ុន្មានឆ្នាំ?

ខ៖ប្អូនញ៉ុម វាឆ្នាំខាល ៩០គត់មិនដឹងយ៉ាង។

ក៖ប្អូនអ្នកមីង២ឆ្នាំ?

ខ៖ទេមិនមែន២ទេ!!៧ឆ្នំា។

ក៖៧ឆ្នាំហេ??ចាំហើយអ្នកមីងរៀបការជាមួយគាត់ប៉ុន្មានឆ្នាំហើយ?

ខ៖អត់មានរៀបការទេ នេះជួបដោយចៃដន្យ។

ក៖នៅឆ្នាំណាវិញមីងដំបូងជួបគ្នា?

ខ៖ឆ្នាំប្រហែលជាឆ្នាំ៩៣(១៩៩៣)មិនដឹងឆ្នាំ៩៤(១៩៩៤)មិនដឹងទេ!!ញ៉ុមភ្លេចព្រោះអីឆ្នាំហ្នឹងពូញ៉ុមអ៊ីញ៉ុមអីគាត់បង្ខិតបង្ខំហាំ!!ហើយប្អូនខ្ញុំស្លាប់ទៅអាទឹមតែស្លាប់ថាដេញអើរម៉ែឪនៅឆ្ងាយហើយណាមួយរូបរាងមិនស្អាតហើយវាចេះតែមកនិយាយពូញ៉ុមទៅណាស់ហើយអ៊ុំញ៉ុមអីហើយប្អូនញ៉ុមអីថាគេអាចពឹងបាន ញ៉ុមថាពឹងមិនបានទេ បើសិនណាវាថាបើសិនវាមានប្តីមានប្រពន្ធវាហ៊ានទទួលគ្រាប់អាកាមួយគ្រាប់។

ក៖ម៉េចហ៊ានទទួលគ្រាប់អាកាមួយគ្រាប់ម៉េចមីង??

ខ៖ខ្ញុំអត់ជឿថាវាមានប្តីមានប្រពន្ធថាវានៅលីវអ៊ីចឹងហាំ!!ហើយវា!!

ក៖ប្តីរបស់អ្នកមីងហ្នឹង?

ខ៖ថា!!

កះប្រាប់ថាគាត់នៅលីវ?

ខះចាំ!!បើសិនណាមានប្រពន្ធ ទទួលគ្រាប់អាកាមួយគ្រាប់។

កះគេអះអាងអីចឹង?

ខះចាំ!! ដល់អីញ៉ុមថាមិនបាច់គ្រាប់អាកាទេ តែមួយកាំបិតខ្វៃក៏បានដែរ វាអញ្ចេក។

កះហ៊ីសាហាវដាក់គ្នាទៀត។

ខះអោយវាឆាប់ចប់។ដល់តែពេលហ្នឹង ដល់តែពេលញ៉ុមថាញ៉ុមសំរេចចិត្តថាអត់យកទេពូញ៉ុមថាចេះតែថាហ៊ីយកវាទៅអានិតវាបើវាមិនទៅណាហើយណាស់!! ហ៊ីញ៉ុមថាកូនពូឯងយកទៅមីស្រីហ្នឹង ញ៉ុមថាអញ្ចឹងហាំ!!ដល់ហើយវាមិនព្រមមិនព្រមពូញ៉ុមនិយាយទៅក៏ញ៉ុមតាមទៅ
ម៉ែឪញ៉ុមអត់ដឹងឮទេរឿងហ្នឹងហ្វូំ!!ហើយដល់ពេលសំរេចចិត្តថាយកបានប្រហែលជាមួយអាទិត្យម៉ែក្មេកហ្នឹងក៏មក ហើយបងថ្លៃញ៉ុមមកស្រែកថាហ៊ីបើសិនណាយកប្រពន្ធមុន ហៃកសុខចិត្តលែងក៏មានមាស៥ហ៊ុន ១ជីដែរណាស់
ហ្បែងដើរយកអីស្រីអញ្ចឹងៗនៅជិតគ្នាហើយក៏ខ្ញុំទ្រាំមិនបានក៏
ហើយពូហោងហ្នឹងនៅក្បែរផ្ទះញ៉ុមដែរថាគេមិនយកចេះតែមករកគេ
ដល់ញ៉ុមថាមីឯងឯងចេញពីផ្ទះញ៉ុមអោយឆ្ងាយណាស់
យកកូនមីឯងឯងត្រលប់ទៅវិញទៅហ៊ីដល់តែស្អែក ទៀតពូហ្នឹងហិនាំផុនៗហ្នឹងហិកូនមួយហ្នឹងមកថាមិនមែនប្រពន្ធកូនទេ
ញ៉ុមថាបើមិនមែនប្រពន្ធកូនញ៉ុមថាស្រីមានការឈឺចាប់ដូចគ្នាណាស់
កុំបាតដៃខ្នងដៃតែប្រទះដាក់ហើយខ្ញុំញ៉ុមថាអញ្ចឹងហាំ!!
អើរស្រីយើងមានការឈឺចាប់យើងនិយាយអោយស្មោះត្រង់ញ៉ុមនិយាយអិចឹងហាំ!!ថាប្តីហ្នឹងទៅធ្វើទាហានប៉ុន្មានឆ្នាំហើយនៅសល់កូនមួយហ្នឹងហិ!!
បងឯងយកគាត់ទៅមានដីភូមិមានអីអីចឹងណាស់!!បានក៏ខ្ញុំសំរេចចិត្តមែនទែនហ្នឹងដល់ក្រោយមកទៀតម៉ែក្មេកញ៉ុំ មមកម្តងទៀតហើយបងថ្លៃហ្នឹងមកវ៉ៃប្តីញ៉ុមហ្នឹងក៏ឃាត់ញ៉ុមទ្រាំមិនបានញ៉ុមទាញកាំបិតដេញកាប់ ញ៉ុមទ្រាំមិនបានអាប្តីញ៉ុមក៏ដេញទៅទាំងប្តីទាំងប្រពន្ធដេញកាប់គ្នាដូចគោក្របីអីចឹ
ងអាហ្នឹងគាត់ថាអើរបើថាប្តីប្រពន្ធហើយត្រលប់ទៅណាស់

បើកុំអោយអាស្រូវពេកហើយក៏អញអាប់អោនកិត្តិយសប៉ុណ្ណឹងក្រវត្តចោលទៅ អញធ្វើសំធឹងតាមសួនក៏បានដែរអញ្ចឹងមែន ដល់ហើយថាមិនមែនទេ!! ដល់អញ្ចឹងទៅញ៉ុមហ្នឹងពោះធំបានបានមួយរយៈក្រោយមកញ៉ុមពោះធំបានកូនភ្លោះ២នាក់ ស្រីទាំង២ ក៏ស្លាប់បាត់ទៅ ។

កះទាំង២នាក់ស្លាប់ទាំង២។

ខះចាំ!!

កះចឹមីងបានស្លាប់?

ខះវាអីចឹងទៅវាកើតមកបាន៣ថ្ងៃមិនដឹងម៉េច!!

កះទាំង២នាក់?

ខះចាំ!!ចេញឈាមតាមច្រមុះរហូត !!

កះហ៊ឺ!!

ខះដល់ពេលអីចឹងទៅប្រពន្ធហ្នឹងក្រោយមកក៏មានចិត្តគេទៅប្ដីឯណាទៅប្រធានភូមិ កាលហ្នឹងយើងនៅភូមិស្ពានទូតស្វៀតហ្នឹង កាលហ្នឹងនៅភូមិទី៧ ក្រុម៨៧គេនោះមិនដឹងក្រុមប៉ុន្មានទេ ខណ្ឌទន្លេបាសាក់ដដែល ចំការមនហ្នឹងប៉ុន្តែខ្ញុំនឹកឃើញថាកូនអាមួយហ្នឹងធ្វើសន្តិសុខតើ!!ដាប្តីហ្អែងគេហៅទៅថាលែង គ្នាជាមួយហ្អែង ថាហ៊ឺលែងៗទៅខ្ញុំមិនដឹងរឿងផងដល់ហើយក៏ថាលែងហើយក៏បាត់ទៅ ក៏ខ្ញុំមិនតាមរកដែរ បាត់ៗទៅ ប្រហែលបានមួយអាទិត្យត្រលប់មកវិញទៀត ត្រលប់មកវិញទៀតម៉ែក្មេកញ៉ុមមក
តាមដានមកឃើញអាហ្នឹងនៅហ្នឹងក៏អត់ទាន់ចូលផ្ទះដែរទៅផ្ទះ
ប្អូនញ៉ុមថាហ៊ឺអញស្មានហ្អែងគេសំល្លេសចោលនៅក្នុងព្រៃកំប្លោកហើយ
ហ្នឹងហើយថាអញ្ចឹងហាំ!!ដល់ប្អូនញ៉ុមថាអញ្ចេកអើរអាំឯងយកទៅវិញទៅគ្មានអាណាគេហៅ អោយមកទេ!!មិនទាន់ឈាមខ្ញុំនៅសរកុំអោយឈាម ញ៉ុមខ្មៅទាន់ប្អូនញ៉ុមហាំ!!ថាអញ្ចឹង ដល់ហើយក៏គាត់ត្រលប់ទៅវិញទៅហើយអាហ្នឹងក៏វាអត់ទៅវិញដែរ។

កះតែប្តីអ្នកមីងបោកអ្នកមីងទេអញ្ចឹង?

ខៈចាំ!!

កៈដំបូងថាអត់មានប្រពន្ធ?

ខៈអត់!!

កៈតែមានហើយហើយ??

ខៈមានប្រពន្ធមានកូនមួយហើយហើយប្រពន្ធហ្នឹងក៏អញ្ចឹងទៀតហើយកាលហ្នឹងហើយអ្នកអះអាងពូឆុនហ្នឹងទៀត
អោយយកកូនទៅជួសឈាមទៀតហើយមិនទៅផងកាលហ្នឹងនិយាយទៅអារឿងប្រវត្តិជូរចត់ហើយ ហ្នឹងហើយដល់ហើយញ៉ុមមានតែប្តីមួយហ្នឹង មានអាណាទៀតទេឥលូវដល់អាយុ៥០ហ្នឹង
ដល់មកក្រោយៗទៀតឆ្នាំដែលឆ្នាំ២០០០ហ្នឹងហើយយើងឆេះបូដេញនេះ!!ខ្ញុំឆ្លងទន្លេមីនេះបាន២ថ្ងៃហើយឆ្លងថ្ងៃសៅរ៍ថ្ងៃអាទិត្យភ្លើងឆេះហ្នឹង។

កៈមីងនៅបូដេញហ្នឹង?

ខៈចាំ!!ភ្លើងឆេះទៅ មីនេះវាកើតនៅថ្ងៃ២៤ខែ ១១ កើតថ្ងៃសៅរ៍ម៉ោង៩កន្លះព្រឹកដល់ថ្ងៃអាទិត្យ ថ្ងៃអាទិត្យហ្នឹងភ្លើងឆេះម៉ោង៣ហ្នឹងបានគេជំលៀសទៅនៅសែនសុខដល់ឥឡូវ នៅអន្លង់ក្ងានហ្នឹង។

កៈចាំ!!

ខៈដល់ទៅហ្នឹងទៅក៏មានស្រីទៀតញ៉ុមនៅកូនង៉ែតហ្នឹងចេះតែចុះឡើ
ងមកភ្នំពេញហ្នឹងមកធ្វើរដ្ឋាករទឹកកាលហ្នឹងហាំ!!
ដល់ហើយមានស្រីមីមួយនៅវត្តប្រយូរវង្សមានស្រីឈ្មោះមីឌីណាមីឌីណា
អាហ្នឹងដាច់មីមួយឈ្មោះមីស្រីហើយ មីស្រីហ្នឹងនៅបូដេញលក់ម្ហូរហើយញ៉ុមតាមទាន់វាថាហ៊ីកាលហ្នឹងញ៉ុមនៅពោះធំមីនេះ
ដល់ហើយវាថាខ្ញុំមិនយកទេញ៉ុមរកលុយអីអីចឹងហាំ!!
ញ៉ុមក៏មិនខឹងគេដែរណាស់!!ខ្លាចអាក្រោយៗបានមីឌីណាទៀតក៏
ខ្ញុំរកវាមិនឃើញក៏ខ្ញុំលែងមាត់ទៅរហូតបានមកនៅសែនសុខហ្នឹងក៏មកលក់លៀសដដែលក៏មកនៅសំបុកចាបបូដេញយើងដដែលហ្នឹង

!!កះគេដេញហើយក៏ទៅយើងមកនៅខាងសំបុកចាបក្រុម៧៨ហ្នឹងដដែលមកនៅលក់លៀស
អ៊ិចឹងៗទៅញ៉ុមទុកកូននេះញ៉ុមជួលគេមើលមួយខែ៣០០០០
មីនេះអាយុបានមួយខួបជាងដល់ហើយវាមានស្រីហិ
ចាប់ផ្ដើមមានស្រីកូនញ៉ុមជូនវាណាមកដឹកខ្ញុំលក់លៀសផងញ៉ុមរាប់សារុងផងកាលហ្នឹងដល់
ពេលហើយកាលហ្នឹងមកដឹកខ្ញុំប្អូនខ្ញុំតែមកបងឯងនៅយូរម្លេះញ៉ុមថាអត់មានម៉ូតូជិះទៅទេ
ព្រោះអីកាលហ្នឹងវាស្វាត់ហាំ!!ហើយម៉ូតូឌុបអីអត់សូវមានទេ
ដល់ហើយចាំញ៉ុមបោះដៃទៅប្ដីញ៉ុមហ្នឹងអោយមកយកខ្ញុំ
ដល់ពេលវាមកយកខ្ញុំម៉ោង៩យប់បាត់ទៅហើយ
មកយកខ្ញុំទឹមដឹកខ្ញុំដល់ផ្សារឡាក់គីអីហ្នឹងស្រីវាតែមកឈ្មោះមីនាងៗស្រីវារោងចក្រនៅរមាស
ហែករាល់ថ្ងៃហ្នឹងតែមកទៅញ៉ុមថាអាឡូម៉េចបានស្គាល់លេខហ្នឹងទាក់ទងគេនិយាយអូនបង
ហ្នឹង ញ៉ុមថាអញរកមុខដូចបួសដឹងប្ដីគេដល់វាភូតញ៉ុមថាហ៊ីមិនមែនស្រីទេ
ហ៊ីម៉ែអាចិត្តនៅបុរីកីឡាថាអ៊ីចឹងហាំ!!ហ៊ីញ៉ុមថាបើម៉ែអាចិត្តម៉េចក៏ហៅបង!!ថាអញ្ចឹង
អាហ្នឹងចាប់ផ្ដើមបាក់បែកគ្នាពេលហ្នឹងហាំ!!ឆ្នាំ២០០៩ដល់ហើយញ៉ុមពោះធំមីនេះ៣ខែហើយ
ដល់ហើយមីអូនអើយយកលុយមកអ៊ីចឹងវាមកជួបមីស្រីរោងចក្រហ្នឹង
មីនាងមីនាងហ្នឹងហៅមីកាផែងនៅស្រុករមាសហែក គ្រញូវមុខដាបហ្នឹង ញ៉ុមថាបើចុះខ្លួន
ចុះតែម្ដងទៅណាស់!!ក៏ញ៉ុមដកយកម៉ូតូមកវិញ
ដកម៉ូតូមកវិញបានមួយអាទិត្យប្អូនថ្លៃញ៉ុមថាអោយគាត់ជិះធ្វើការទៅបានមួយអាទិត្យហ្នឹងក៏
អោយវាធ្វើការជិះទៅធ្វើការ
បើកលុយបានផ្ញើរមកអោយខ្ញុំ២០រៀលវាបើកលុយបើកប្រាក់ខែបាន៣ង្រត់គ្នាទៅតែម្ដងទៅ
ទៅនៅរមាសហែកហ្នឹងថ្ងៃអើរឆេះរ៉ូយ៉ាល់ហាំ អារ៉ូយ៉ាល់គេបាតុកម្មហ្នឹង
វាត្រលប់មកវិញត្រលប់មកវិញហ្នឹង វ៉ៃគ្នាមួយសារឈប់ហើយថាដាច់គ្នា
ថាសារហ្នឹងដាច់គ្នាមែនទែន ញ៉ុមក៏ដកម៉ូតូយកទៅលក់ទុកលុយចិញ្ចឹមកូន
ដល់ពេលហើយអញ្ចឹងទៅអាហ្នឹងញ៉ុមពោះធំញ៉ុមមកលក់លៀសលក់ខ្មៅហើយកូននេះនៅទូ
ចមីនេះនៅទូចដែរហាំ!!កះចាំ!!ខះតែមីនេះនៅ
ដល់ពេលលក់លៀសលក់ខ្មៅកើតទៅមីនេះនៅង៉ែតអោយមីបងមើលកាលកូនញ៉ុមនៅទូចៗ
ណាស់ អើរអោយមើលចុះឡើងទៅមីនេះកើតមកបានចេះសើចអាហ្នឹងត្រលប់មកវិញ
ហ៊ីប្អូនបង្កើតៗអត់អោយបាយស៊ីទេដល់ខ្ញុំនៅជាមួយប្អូនខ្ញុំអាប្រុសមកទៅប្អូនញ៉ុមក៏ចិត្តដាច់
ស្អីទេអោយគាត់ហូបទៅ
ម៉ែមីម៉ុចហិ!!អើរបើគាត់មិនទៅណាគាត់នៅអង្គុយសំកុកមុខឡើងខ្មៅអ៊ីចឹងហាំ!!ក៏អោយទៅធ្វើ

ការ
ព្រយ៉ុងៗទៅណាស់អោយទៅធ្វើការសំនង់ហៅទៅធ្វើការបានមួយអាទិត្យបើកលុយបានព្រុច ទៅទៀតទៅហ្នឹងទៀត គ្មានអោយកូនចាយណា!!

កៈឆ្អែតឆ្អល់ម៉េច!!

ខៈហើយក៏ផ្ញើរនៅប្អូនថ្លៃញ៉ុមអោយ១០០០០ថាទៅ២
៣ថ្ងៃត្រលប់មកវិញហាំ!!ទៅរហូតទៅតែម៉ងទទួលឮថាខ្ញុំលក់អីបានលុយអ៊ីចឹងទៅញ៉ុមមកជួ លផ្ទះនៅទីនេះ ក៏ប្អូនថ្លៃញ៉ុមមកនៅជាមួយខ្ញុំដែរឈ្លោះគ្នាម៉េចក៏ត្រលប់មកវិញទៀត ហ៊ីត្រលប់មកវិញទៅទារខ្ញុំថាអញ្ចេកទិញម៉ូតូទៅអើយអញរត់ឌុប
បានជួយលុយគ្នាអ៊ីចឹងទៅមីអូន!!

កៈចាំ!!

ខៈកូនញ៉ុមមីនេះវានៅទូចវាតាមដានអាលុយលៀសគេគ្រាន់តែទុកមួយភ្លេតលាក់លួចទុកផ្ញើរ ទៅអោយមីហ្នឹងហាំ!!កូនញ៉ុមថាម៉ែនោះប្តីម៉ែឯងលួចលុយទៀតហើយថាអញ្ចឹងហាំ!!យើងបា ត់លុយមួយភ្លាត
មួយភ្លាតបាត់មួយខ្ទៀសមួយភ្លាតបាត់មួយខ្ទៀសលួចលុយដាក់តាមអានេះលាក់តាមជើងខោ !!ប្អូនថ្លៃញ៉ុមរើសបាន១០០០០០ហាំ!!ហុចមកអោយខ្ញុំវិញ ហ៊ីក្រោយមកទៀតមីអូន ហ៊ីអញលែងរត់ម៉ូតូឌុបហើយអាហ្នឹងនិយាយប្រវត្តិហាំ!!ក៏សុំការធ្វើសន្តិសុខ
ញ៉ុមឮគ្រាន់តែថាឮធ្វើសន្តិសុខប្រាក់ខែញ៉ុមសួរពូញ៉ុម ពូញ៉ុមតេទៅគាត់ធ្វើការ ញ៉ុមពូហិ!!មានការងារអីអោយវាធ្វើទេ មានខាងសន្តិសុខរោងចក្រ គាត់ថាមាន តែយាមចល័ត អើរបើមានប្រាក់ខែប៉ុន្មាន?? គាត់ថាចូលដំបូង៩០ ដល់៩០ក៏វាព្រមធ្វើណាស់ យកម៉ូតូហ្នឹងជិះទៅធ្វើការ
បើកលុយបានយកអាម៉ូតូហ្នឹងទុកផ្ទះផ្ញើរនៅហ្នឹងទៅជាមួយស្រីបាត់នៅខេត្តពោធិសាត់ បាននៅខេត្តពោធិ៍សាត់ហ្នឹងបានមីប្រពន្ធនៅរមាសហែកហ្នឹងតេមកញ៉ុមសុំទៅដុតភ្លើងអោយ កូន ថាគ្មានអ្នកណានៅទេបងអើយញ៉ុមខុសហើយអើយ អោយតាខ្មៅទៅដុតភ្លើងអោយខ្ញុំទៅ ខ្ញុំថាអញមិនដឹងទេវាមិននៅហ្នឹងទេវាមានស្រីទៅនៅខេត្តពោធិ៍សាត់ទៀតហើយឥឡូវ!!

កៈប្រពន្ធចុងមួយទៀតហ្នឹងតេមកមីងទៀត?

ខៈចាំ!!

កះហ៊ីក៏វាយអីគ្រប់ម្លេះពូហ្ន៎!!

ខះមីមួយនៅរមាសហែកមីមួយនៅរោងចក្រហ្នឹងហាំ!!ក៏ខ្ញុំទៅតែទៅ ចិត្តមិនដាច់ទៅថាហ៊ីឪមីងចអើយម៉ែមីខ្ទុចឆ្លងទន្លេម្នាក់ឯងឥឡូវទៅដុតភ្លើងអោយវាទៅបើឪមី ម៉ុចឯងចង់មករកស៊ីនៅភ្នំពេញដុតភ្លើងហើយក៏មកទៅ ចិត្តល្អអ៊ីចឹងហាំ!!

កះហ៊ី!!

ខះដល់តែមកទៅមក មកទៅក៏ខ្ញុំថាបានលុយមកញ៉ុមអោយ៥០០០០ត្រលប់ទៅវិញទៅ ត្រលប់ទៅស្វាយរៀងហ្នឹង ហ្នឹងបានអ៊ិចឹងទៅទៅធ្វើស្រូវធ្វើអង្ករទៅ ហើយម៉ែក្មេកប្អូនថ្លៃញ៉ុមក៏ច្រូត ដល់ឈ្លោះគ្នាម៉េចទេជេរមកដល់ខ្ញុំដល់ប្អូនថ្លៃញ៉ុមថាអញ្ចេក ទៅជេរអីដល់បងដាបងដាគាត់ដឹងអី??បើយកប្ដីគេ
គេអោយមកហ្នឹងស្រួលទៅជេរអីដល់គាត់ទៀត គាត់មិននឹកដើមទេណាស់ ដល់ម៉ែក្មេកញ៉ុមទៅថាហ្អែងលួមកិនអង្ករអោយអើរកូនស៊ីផងទៅ
ដល់មីហ្នឹងថាហ៊ីអោយស៊ីធ្វើអី??មកធ្វើស្រូវអង្កាល់អោយផ្ញើរទៅហ្នឹង!!
បើអោយញ៉ុមចង់បានញ៉ុមអត់ចង់ទេ តែម៉ែក្មេកញ៉ុមនិយាយអ៊ីចឹង ដល់អាហ្នឹងវាឮអ៊ីចឹងថាង៉ែងនៅទៅនៅម្នាក់ឯងទៅអញលែងនៅហើយរហូតតាំងពីហ្នឹងមកវារ ត់មកហ្នឹង
ដល់រត់មកហ្នឹងក៏ញ៉ុមសុំថាទៅធ្វើការនៅផ្លាហ្សាធ្វើណាស់!!សុំការងារអោយធ្វើហ្នឹងទៅនិយា យអ៊ីចឹងយើងរៀងនិយាយកាត់ មកមកលេងអ៊ីចឹងមានតែអាវយឺតសរមួយនេះ គេខោខ្មៅនេះ បងរិទ្ធនេះ ហាងហើយហាងង៉ែងយកវាម្តងទៀតទៅក្រែងលោវាកែថាអ៊ិចឹងហាំ!!

កះហ្ន៎រ៉ាប់ដងមិនឈ្នះហើយមីងអើយ!!

ខះក្រែងលោវាកែ ញ៉ុមថាហ៊ីឆ្កែវាមិនដែរកែទេមីរិនហេំ!!ញ៉ុមថាអញ្ចឹង ហ៊ីង៉ែងសាកម្តងទៀតទៅណាស់ញាតិមិត្តអីថាអ៊ីចឹងទៅ ញ៉ុមថាក៏អញ្ចឹងក៏អញ្ចឹងទៅ អាហ្នឹងអោយមកនៅវិញទៅហើយ មកនៅហ្នឹងទៅធ្វើការ គ្រាន់តែត្រឹមផ្លាហ្សាយើងដើរមិនដល់!!

កះចាំ!!

ខះពីហ្នឹងទៅ។

កះជិតហ្នឹង។

ខះរកកង់ជិះ ខ្ញុំក៏យកកង់ប្អូនញ៉ុមអោយមកយកទៅធ្វើការណាស់ អស់ពីកង់សន្សំលុយទិញអារីវ៉ាហ្នឹងហិ ហ៊ីដល់បានម៉ូតូនៅជំពាក់លុយគេហ្នឹងហិរាប់ខែអត់អោយ មួយខែអត់ មួយខែអត់ទៅនៅផ្ទះនោះលុយថ្លៃក៏អត់អោយដែល ហ៊ីគាត់ថាហ៊ីម៉ែមីងុយអើយមកដូរផ្ទះ ដូរផ្ទះផ្ទះហ្នឹងហិ!!អោយញ៉ុមដូរអាឆ្នាំ២០១២ហ្នឹង បើមិន១២ ១៣(២០១២ ២០១៣)ហ្នឹងហិ ញ៉ុមចាំរហូតមកមីអូនវាមិនដែលអោយទេ ចុងក្រោយវាមកដៀលយើងថាស្រីមិនកើត លក់មួយឆ្នាំៗជំពាក់តែគេរកលុយមិនបានអ៊ីចឹងហាំ!!

កះយេ!!

ខះហើយឈឺចាប់អត់??កះចាំ!!ខះសូម្បីតែកូនវាមិនដែលអោយលុយទេដល់ឥលូវហ្នឹងតិចថាជួបគ្នារាល់ថ្ងៃអោយលុយ
យកលុយទៅអោយតែប្រពន្ធនៅរមាសហែកហ្នឹងរហូតដល់ម៉ែក្មេកហ្នឹងថាខ្ញុំហ្នឹងអត់កើតដែរ ហ៊ីប្រពន្ធកាលអាកាល លើកមុនទៅជួយព្រួតវ៉ៃជាមួយញ៉ុមហាំ!! ដល់ឥឡូវអានេះមីនោះថាបងឯងចាំមើលញ៉ុមទៅរកស្នេហ៍ដាក់យកមីមួយមីវីនៅវត្តដំបូកខ្ពស់ ហើយ ទាន់ដូចញ៉ុមប្រាប់មីអូនឯងសារមុនអ៊ិចឹងញ៉ុមខ្ជិលរាប់រៀបទៀត ដល់ហើយបងអើយទៅព្រួតវ៉ៃ
ញ៉ុមថាក្បាលអាណាសក់អាហ្នឹងអំពើអាណាសាងអាហ្នឹងទទួលទៅ
សម័យនេះមិនចាំបាច់អង្កាល់ទៀតទេណាស់!!កះចាំ!!ខះមិនបាច់ចាំយើងចងកម្មចងពារទៀត ទេពីណាសាងអីទទួលហ្នឹងទៅលទ្ធផលណាស់មីអូនយើងនិយាយអ៊ីចឹង
!!ហ៊ីបងឯងចំមើលញ៉ុមទៅរកគ្រូដាក់ទៀតហាំ!! អើរបើដាក់បានក៏ដាក់ទៅញ៉ុមថាអ៊ីចឹងណាស់ !!

កះប្រពន្ធគាត់មួយផ្សេងទៀតហ្នឹង?

ខះនៅរមាសហែកហ្នឹងហាំ!! ដាក់បំបែកពីមីមួយនៅដំបូកខ្ពស់នេះ ហ៊ីដល់ឥឡូវអាហ្នឹងវាមិនទៅទេ ប៉ុន្តែដូចថាវាត្រូវរបស់គេរបស់មីហ្នឹងមិនដឹង បានកូន២នៅហ្នឹងហា ក្រមុំកំលោះដែរហើយឥឡូវហ្ន៎!!លុយផ្ញើរទៅតែហ្នឹង រាល់ថ្ងៃបើថាកូននេះគ្មានទេ ហើយក៏គ្មាននឹកថាជាប់សាច់ឈាមអីនឹកថាកូនដែរ

ដល់ខ្ញុំទៅផ្លាហ្សានេះពួកអ្នកលក់បន្លែសួរថាញ៉ុមអញ្ចេក
អើរកាលហ្នឹងញ៉ុមដេញកាប់ដេញអីផ្អើលផ្លាហ្សាណាស់
អ្នកលក់បន្លែសួរញ៉ុមថាអញ្ចេះ!!ហ៊ីអ៊ីអ៊ីអាតាមួយខ្មៅតា១៨ហ្នឹងប្ដីអ៊ីឯងមែន?
ញ៉ុមថាគ្មានប្ដីខ្ញុំនៅហ្នឹងទេ!!ដាច់ស្រេចហើយ អ៊ីឯងដាច់ស្រេចហើយហីអី?ញ៉ុមថាដាច់ហើយ
ដល់ហើយអ៊ីចឹងបានគេទាក់ទងមីមួយលក់នំបញ្ចុករាល់ថ្ងៃឡើងស្អិតរមួត
យើងនិយាយតាមគេណាស់
ដល់ហើយញ៉ុមថាមកពីណាងាយចេះតែអោយវាទៅអាហ្នឹងវាល្អ១០០នាក់អោយតែសំបូរអោយវាទៅ !!និយាយអ៊ីចឹងមីអូនហ្វើយ!មែនស្មាទោស។

ក៖ហើយនិយាយថាឥឡូវប្រពន្ធ ហាប្ដីរបស់មីងហ្នឹងហាំសរុបប្រពន្ធប៉ុន្មាននាក់ហើយមីង?

ខ៖ហ៊ឺអាថាដើមហ្នឹងមួយណាស់!!ញ៉ុមពីរ មីស្រី៣ មីឪណាហ្នឹង៤ អាហ្នឹងញ៉ុមស្គាល់ឈ្មោះហាំ!!

ក៖ចា!!

ខ៖មីនាងហៅមីផេងហ្នឹង៥ ៦មីនៅជំបូកខ្ពស់ ៧មីនៅផ្លាហ្សាហ្នំ ហើយចុះមីនៅសៀមរាបមីនៅស្រុកអី ព្រៃវែង អង្គរគ្រេតវាចូលជាង១០នាក់ហើយ។

ក៖ចំម្លឹងៗលោក !!ចុះឥឡូវទីបញ្ចប់ចុងបញ្ចប់នៅជាមួយអ្នកណាគេ?

ខ៖ចុងបញ្ចប់ញ៉ុមមិនដឹងដែរ ថាកំពុងទាក់ទងមីណានៅផ្លាហ្សាទៀតញ៉ុមមិនដឹងទេ !!

ក៖យីអីក៏ម្ល៉េះៗ លោកម្ចាស់ហើយលោក អីក៏!!

ខ៖ហើយនៅវែងឆ្ងាយទៅមុខទៀតខ្ញុំក៏មិនដឹងទេ!!

ក៖ហើយគាត់ទឹមអាយុទឹម៤០ជាងទេហេ??

ខ៖ទឹម៤០ជាង ៤១ ៤២ គិតទៅ។

ក៖យេអីក៏ម្ល៉េះៗ !!

ខ៖រាល់ថ្ងៃហ្នឹង អស់ការនិយាយ។

កះចាំហើយមីងដំបូងឡើយអត់ទាន់ស្ទូវស្រលាញ់ទេហីគង់បងប្អូនអីវ៉ាន់បង្ខិតបង្ខំអីចឹងទៅណោះ?

ខះចាំ!!

កះហើយជឿតាមសំដីគេថាគាត់ជាមនុស្សល្អមនុស្សអីអិចឹងទៅណោះ?

ខះចាំចាំ!!!

កះតែកំរមានមនុស្សប្រុសអីចឹងណាស់មីងមែនទេ??មកធ្លាក់ចំមីងនេះហិ!!

ខះខ្ញុំដេញបាញ់ទៀតហ្ន៎!!

កះបានកាំភ្លើងពីណាដេញបាញ់?

ខះកាំភ្លើងកាលហ្នឹងពួកធ្វើការនៅខាងក្រុមហ៊ុនហ្នឹងគាត់ទុកនៅនឹងឃ្លាំង កាំបិតផ្តេកអីសំបូរ ខ្ញុំដេញបាញ់ម៉ោង៩ល្ងាច រត់បាស់ជើងសរព្រាត។

កះចំមីងជើងឆៅផង មីឆ្នាំរកទៀតចិត្តឆៅ !!

ខះញុំមខឹងក្តៅក្រហាយ។

កះទាំងគេទាំងយើងមីងណេះ??

ខះហ៊ីឈឺចាប់ណាស់។

កះតែឥឡូវម៉េចដែរមីង កាត់ចិត្តអីវ៉ាន់បានហើយហេ៎??

ខះអត់មានទេអូនហ្វើយដាច់ស្រលះស្អាតផែង!!

កះហ្នឹងហើយ។

ខះគ្មាននឹកនាអីទេ។

កះចុះបើសិនមកម្តងទៀតអីមើលទៅទទួលទេ?

ខះអត់ទេ!!

ក៖ជឿទៀតទេ?

ខ៖មិនជឿទេ វាច្រើនសារហើយ ជឿអីហ្អែងគិតទៅ ឥឡូវយើង៥០ហើយនៅសន្សំកម្មអីទៀត យើងគិតតែពីកូនចៅយើងទៅ។

ក៖ហើយអ៊ីចឹងអត់មានអ្នកណាគេលួចស្រលាញ់សុំស្រលាញ់អីទៀតទេហី?

ខ៖គ្មានទេ។

ក៖អត់ទេហ៎?

ខ៖ចាំ!!

ក៖ឥឡូវនៅស្រលះផែងម៉ងហោ?

ខ៖ស្រលះផែង។

ក៖ហ្អើយយ៉ាប់ណាស់!!

ខ៖ថាមួយជាតិហ្នឹងមានតែមួយហ្នឹង។

ក៖ចាំ!!

ខ៖គ្មាន២ ៣ទេ!!

ក៖តែមួយហ្នឹងមួយកំពូលម៉ងមីហោ??

ខ៖ចាំ!

ក៖ហើយកាលពីដំបូងចូលមកសុំមីងស្រលាញ់ គេមានអោយថ្លៃជំនួនថ្លៃអីអោយទេ??

ខ៖ហ៊ីប្រាប់ថាជួបដោយចៃដន្យ។

ក៖គេអត់មានអោយថ្លៃអីគេដែរម៉ងហោ??

ខ៖អត់ទេ តែអោយញ៉ុមសែនញ៉ុមមិនសែនផង ញ៉ុមថាអត់!!

ក៖ចាំ!!

ខ៖រវល់!!ខ្ជិល!!

ក៖អ៊ីចឹងតាមដំនើរទៅ?

ខ៖ហ្នឹងហើយ ញ៉ុមថាយកងាយលែងក៏ងាយដែរនឹកឃើញ ម៉ែឪមិនដឹងផង ដឹងតែអំញ៉ុមពូញ៉ុម។

ក៖នៅស្រុកនៅអីណោះមានអ្នកស្រលាញ់ដែរ?

ខ៖មានច្រើន!!

ក៖ហើយម៉េចមិនទៅ??

ខ៖ចង់ត្រូវការអត់ចង់ បើបងប្អូនជីដូនមួយញ៉ុមហ្នឹង ២ ៣នាក់ញ៉ុមអត់ចង់បាន!!

ក៖ចាំ!!

ខ៖កូនអ៊ុំញ៉ុមទាំងអស់ ឥឡូវបងវណ្ណស្លាប់ហើយ។

ក៖បើសិនជាអ្នកនៅស្រុកនោះសុំស្រលាញ់បានសមប្រកបជាងមីងណោះ??

ខ៖អត់មានចិត្តនិយាយរួម អត់ចង់ផង។

ក៖សំខាន់គឺបេះដូងមីងហោ??

ខ៖អាហ្នឹងក៏មិនចង់ដែរដោយសារអំពូអីគាត់ថាហ្អែងនៅធ្វើអីទៀតហាង??ចំណាស់នេះហើយ។

ក៖ពេលមីងរៀបការហ្នឹងអាយុប៉ុន្មានវិញ?

ខ៖មិនដឹងទេ ភ្លេចហើយ!!មិនដឹងប៉ុន្មាន!!

ក៖តែដឹងតែ៩៣ (១៩៩៣)៩៤(១៩៩៤)ហ្នឹង??

ខ៖៩៣ ៩៤(១៩៩៣ ១៩៩៤)។

កៈចាំ អ៊ីចឹងមីងមីងសំរាប់ចូលដល់ការសិក្សាមីងវិញម្តងមីងរៀនបានថ្នាក់ទីប៉ុន្មានដែរមីង?

ខៈខ្ញុំរៀនម៉ាជំនាន់ហ្នឹង ខ្ញុំរៀនពី៧៩(១៩៧៩)ដល់ឆ្នាំ៨០ជាង(១៩៨០) ៨៦(១៩៨៦)ញ៉ុមឈប់ប្រលងសាលា សាលាកាលេសតាគោក ខ្ញុំខ្ជិលជិះកង់ខ្ញុំឈប់ទៅ។

កៈតែបានថ្នាក់ទីប៉ុន្មានដែរមីងកន្លែងហ្នឹងគេហៅថ្នាក់ទីប៉ុន្មាន?

ខៈទី៦។

កៈហ្អូទី៦ដែរ!!!មីងមានរៀនភាសាអីក្រៅពីភាសាខ្មែរទេ??

ខៈរៀនតែភាសាខ្មែរ។

កៈគេអត់មានបញ្ចូលបារាំងទេហេ?

ខៈអត់ទេ!!កាលហ្នឹង។

កៈចាំ!!

ខៈជំនាន់ហ្នឹងអត់ទាន់មាន។

កៈអានភាសាខ្មែរហ្នឹងអ្នកមីងអានវិលម៉ងហេ??

ខៈកាលញ៉ុមនៅរៀនញ៉ុមអានវិល។

កៈតែឥឡូវមានភ្លេចខ្លះអត់?

ខៈឥឡូវមើលអត់ឃើញ។

កៈភ្នែកអត់ស្រួវបានហេ៎??

ខៈចាំ!!មើលទៅបែកផ្សេង។

កៈតែអត់មានកាត់វ៉ែនតាអីពាក់ណាហី?

ខៈអត់!!

ក៖ចាំ!!ហ្នឹងហើយ ចុះអ្នកមីង អ្នកមីងចាំថាអ្នកមីងពេលនៅរៀនរៀននៅសាលាឈ្មោះអីគេទេ??

ខ៖សាលារៀន សាលាវត្តហារ។

ក៖វត្តហារនៅព្រៃវែងហ្នឹង?

ខ៖ហ្នឹងហើយ។

ក៖ពេលអ្នកមីងរៀនហ្នឹងមានពួកម៉ាក់អីច្រើននាក់អីអត់មីង?

ខ៖មានតែសិស្សរួមថ្នាក់ទាំងអស់គ្នាហ្នឹង ញ៉ុមមិនដែលមានពួកម៉ាក់ទេពេលនៅរៀន!!

ក៖ជិតស្និតអីវ៉ាន់អត់មានទេហី?

ខ៖មានតែជីដូនៗមួយហ្នឹង មានណា!!

ក៖អ៊ីចឹងប្រហែលជាបន្តិចទៀតនិយាយអំពីប្រវត្តិរបស់អ្នកមីងនៅក្នុងសម័យសង្គ្រាមហាំ!! មីងគឺមីងកើតទាន់១៩៦៨ហ្នឹងគឺទាន់សង្គ្រាមហើយ!!

ខ៖ហ៊ីញ៉ុមនៅទូចម៉េចដឹង!!! បើ៧៩(១៩៧៩)អីគ្រាន់តែដឹង។

ក៖ចាំ!!អ៊ីចឹងមីងសំរាប់នៅក្នុងជំនាន់ប៉ុល ពតអីវ៉ាន់អ៊ិចឹងហាំ មីងមានចាំអីគេបានខ្លះអ្នកមីងអាចនិយាយប្រាប់ទាំងអស់មក!!

ខ៖ជំនាន់ប៉ុល ពតញ៉ុមចាំបានខ្លះ។

ក៖និយាយប្រាប់មក។

ខ៖ព្រោះអីញ៉ុមអាយុបែកភ្លាមញ៉ុមអាយុ១១ឆ្នាំ!!

ក៖ចាំ!!

ខ៖តែពេលឆ្នាំមើល!!៧៨ ៧៩(១៩៧៨ ១៩៧៩)ហ្នឹងដើមឆ្នាំ៧៩(១៩៧៩)ញ៉ុមទៅទាន់អាកន្លែងគេ ញ៉ុមទៅបេះព្រីងស៊ីខែវស្សា ឃើញគេចងមនុស្សនៅដើមព្រីងអ៊ីចឹងតែយើងនៅក្មេងហាំ!!

វះពោះអ៊ិចឹងនៅក្អែកម៉េចៗកុំពុងតែស្រែក ដល់មកស្រែកទៅប្រធានគេដឹងថាបែកការគេរកចាប់យើងសម្លាប់ចោលហាំ!!

កះចំ!!

ខះដល់ហើយអ៊ំញ៉ុមមួយគាត់មេកងធំ
តាញ៉ុមមេកងទូច!!ដល់ហើយពូញ៉ុមគាត់ប្រធានភូមិក៏គាត់
ជំលៀសខ្ញុំអោយមកនៅកន្លែងប៉ាញ៉ុមកាប់អុសនេសាទត្រីហ្នឹង
ដល់ពេលហើយវាជិតនេះហើយ ជិត ក៏អោយញ៉ុមមកនៅឯស្រុកពាមជ មកនៅផ្ទះអ៊ីញ៉ុម
ដល់ពេលគេរៀងសាបអ៊ិចឹងអោយញ៉ុមចូលត្រលប់ទៅវិញហ្នឹងអ៊ីចឹងទទួលចូលដល់ថាដូចខែមករាអ៊ិចឹងហាំ!!
គាត់បញ្ជូនញ៉ុមត្រលប់មកវិញអ៊ិចឹងញ៉ុមមិនដឹងដែរដល់ពេលហើយប៉ាញ៉ុមទៅប្រាប់ម៉ែញ៉ុមថាអញ្ចេក ហ៊ីគេជំលៀសអីទៅណា!
កុំទៅនាំកូននៅតែក្នុងផ្ទះហ្នឹងហើយចាំប៉ាត្រលប់មកចាំទៅទាំងអស់គ្នាអ៊ីចឹងហាំគេមកកៀរប្រជាជននៅឯភូមិអ៊ីចឹងអោយទៅអ៊ីចឹងទៅណាស់ តែប៉ាញ៉ុមមកប្រាប់មុនថា
ប៉ាញ៉ុមគាត់មកពេលយប់អ៊ិចឹងគាត់មកភ្លាមគាត់ត្រលប់ទៅវិញភ្លាមហ្នឹងថាកុំអោយទៅ
ញ៉ុមចាំថាប៉ាញ៉ុមមកប្រាប់ម៉ែញ៉ុមថាកុំអោយទៅណានៅតែផ្ទះហ្នឹងហើយចាំគាត់មក
បើគេមកហៅថាចាំប៉ាញ៉ុមមកចាំទៅជុំគ្នាអ៊ីចឹង!!

កះគេអនុញ្ញាត!!

ខះហ៊ី??

កះគេអនុញ្ញាតដែរ អនុញ្ញាតអោយចាំដែរ?

ខះប្រាប់អ៊ីចឹងប្រាប់ប្រធានភូមិប្រាប់ថាប៉ាញ៉ុមថាអញ្ចឹងទៅ
ដូចថាវានៅទាញអូសប្រលាយអ៊ីចឹងហា!!ដល់ហើយថាមួយថ្ងៃជៀសមួយថ្ងៃមួយថ្ងៃជៀសមួយថ្ងៃទទួលអាថ្ងៃមួយនោះម៉ែញ៉ុមទៅច្រូតស្រូវហ្នំ!!អ៊ំញ៉ុមអីនៅពេងយាយៗហ្នឹង
អាថ្ងៃបែកហ្នឹងហិកប៉ាល់ហោះ
ហោះវែលហ្អែងពេញហ្នឹងនៅភូមិហ្នឹងហាំ!!ច្រើនហើយមួយសន្ទុះក្រោយមកខ្ញុំហ្នឹងក៏រត់ទៅលេងតាមផ្លូវរទេះហ្នំ!!៣ ៤ ៥នាក់អីជាមួយបងថាអីទៅ
មួយសន្ទុះឃើញអាឡានអាកម្ម៉ង់ទូចៗមក៧ ៨

អាកម្ម៉ង់ការអ៊ិចឹងទៅគេថាហ្វយួនចូលស្រុកហើយអ៊ីចឹងហាំ!!យួនមកហើយដល់ហើយទាហានបាក់ទ័ពមកពីខាងណោះរត់ឈូអ៊ិចឹងទៅញ៉ុមក៏មិនដឹងដែរចាស់ៗថាទាហានបាក់ទ័ពមកពីខាងស្វាយរៀងចាស់ៗនិយាយថាអញ្ជឹងហាំ!!

កះចាំ!!

ខះហើយយើងនៅក្មេងៗយើងអត់ដឹងទេ!ថាហុីទាហានបាក់ទ័ពហើយយើងរត់ទៅផ្ទះថាអញ្ជឹងហាំ!!ក៏ត្រលប់មកផ្ទះទៅក៏ពួកយួនហ្នឹង៧ឡានហ្នឹងកំពុងចូលវត្ត
ចាស់ៗបេះដូងគាត់អាខ្លះគាត់ចេះភាសាវៀតណាមហ្នឹងគេនិយាយទៅ
បេះដូងហ្វបទៅក៏គេប្រាប់ថាមិនបាច់ទៅណាទេបងប្អូនអ៊ិចឹងហាំ!!
អ្នកបកប្រែញ៉ុមឈរស្តាប់អ៊ីចឹងទៅអត់បានគៀរទៅណាទេ!!ទទួលប៉ាញ៉ុមមកល្ងាចអ៊ិចឹងទៅ!!

កះហុីៗ!!

ខះក៏ប្រជាជនភូមិញ៉ុមគេអត់បានគៀរឡើងទៅតាមមាត់ទន្លេទេអត់បានទៅទាំងអស់មួយភូមិហ្នឹងហ្វ៎!!

កះចាំ!!ជំនាន់ប៉ុល ពតមីងនៅព្រៃវែងហ្នឹងដដែល?

ខះនៅភូមិហារហ្នឹងដដែល។

កះហ្វ៎គេអត់ជំលៀសទៅណាទេហេ??

ខះអត់ទាន់បានជំលៀសទេនៅ គេថាពេលល្ងាចគេហ្នឹងហ៎ គេគៀរទៅគេថាចាំស្អែកទៀតតែយប់គេប្រជុំមួយយប់២ ៣ដងហ្វ៎!!

កះហ្វ៎!!

ខះតែអត់បានទៅក៏ទៅច្រូតទៀត ម៉ែៗទៅច្រូតទៀតគេអោយប៉ាញ៉ុមមកប្រាប់អីអ៊ីចឹងទៅ!!គេអត់បានគៀរទៅថាស្អែកឡើងគៀរទៅទទួលថ្ងៃ៧មកពាហ្នឹងវា!!

កះបែកទៅ??ចាំ!!

ខះវាចូលមកដល់ព្រឹបៗទៅ បាត់ទៅ។

កះចុះពេលមុនអាមុនជំនាន់បែកហ្នឹងមីងនៅក្នុង៧៥(១៩៧៥)៧៦(១៩៧៦)៧៧(១៩៧៧)៧៨(១៩៧៨)នោះអីវ៉ាន់ម៉េចទៅមីង?

ខះឆ្នាំ អាដើមឆ្នាំ៧៨(១៩៧៨)វាមិនសូវចាំ អាឆ្នាំ៧៨(១៩៧៨)មានស្អីនៅក្មេងៗតូចៗដូចគ្នាគេហៅទៅស៊ីបាយរួមអីហ្នឹង ដាក់អាដើមចេកធ្វើក្បូនឆ្លងទៅស៊ីបាយរួមតែវាអត់មានបញ្ហាអី!!ហើយយើងមានកូនផ្តិលមួយៗអីចឹងទៅដាក់លើភ្លៅស៊ីបាយរួមតុអីចឹងទៅ គេមើលមិនទាន់ប្រធានរោងបាយគេមើលមិនទាន់ដួលបាយញ៉ុកចូលផ្តិលលាក់សិន ទុកយកមកស៊ីផ្ទះពេលយើងឃ្លាន់ទៀតនោះ!!

កះអូយ !!តែគេមើលអត់ឃើញដែរមីងណោះ??

ខះគេមើលអត់ឃើញ បើគេមើលឃើញគេចាប់វ៉ៃហាំ!!ជំនាន់ហ្នឹងតែមើលអត់ឃើញ។

កះចាំ!!ហូបឆ្អែតច្រើនទេមីងពេលហ្នឹង?

ខះហូបឆ្អែតតើអត់មានខ្វះខាតទេ តែគេអត់អោយយកចេញមកក្រៅ!!

កះហ្នំ!!តែកន្លែងខ្លះពិបាកណាស់មីងមែនទេ??អីចឹងមីងសំណាងហើយអីចឹង។

ខះកន្លែងខ្លះឮគេថាពិបាក តែភូមិញ៉ុមអត់អី តែម្ហូបបរបូរ បាយអីគ្រាន់តែថាវាមិនស្រួយគ្រាន់តែបបរប៉ិៗ។

កះហ្នំ!!អីចឹងអ្នកមីងធ្វើការអីគេខ្លះនៅពេលជំនាន់ហ្នឹង?

ខះញ៉ុមគេប្រមូលផ្តុំតែញ៉ុមនៅទូចៗជាងគេ គេអាយុដូចៗខ្ញុំគេប្រមូលផ្តុំគេអត់អោយដេកនៅជាមួយម៉ែឪទេ!!គេទៅអោយដាក់មួយដុំហើយជំនាន់ហ្នឹងក្មេងៗអីចឹងដូចខ្ញុំអីចឹងគេអោយស្ល្យៀ កខោខ្លីពណ៌ខ្មៅត្រឹមហ្នឹងចងខ្សែមុខហ្នឹង ហើយអាវពណ៌ប្រផេះតែមួយកំផ្លេៗហ្នឹងមានអោយច្រើនឯណា!!

កះចាំ!អីចឹងគេអោយមួយកំផ្លេឬក៏ពីរកំផ្លេមីង??

ខះមួយកំផ្លេ។

កះហើយដូរអីវ៉ាន់ម៉េចទៅ??

ខះយើងមានដូរអីអាខោអាវយើងអាចាស់មាននោះ!! ចេះតែផ្លាស់ប្តូរ
ហើយជំនាន់ហ្នឹងងូតទឹកស្រាតដែរនិយាយអោយឃើញទៅនៅទូចៗ។

កះទូចៗមិនអីទេមីងហេ៎??

ខះចា៎!!

កះកុំអោយតែធំៗ ។

ខះនៅទូចៗទាំងរ៉ូងៗនាំគ្នាលោតទឹកព្រោងៗ
ស្រាតហើយអាខោយើងហ្នឹងស្លៀកវិញទៅមានគិតអី!!និយាយអោយអស់កេរ្តិ៍ទៅ!!

កះចា៎!!មានសាប៊ូដុសទេពេលជំនាន់ហ្នឹង?

ខះគ្មានទេ!!គ្មានទេ!!

កះអូយវេទនាណាស់មីងអើយ!!

ខះមានសាប៊ូមានអីមកពីណា
ងូតទឹកឡើងព្រោងងូតស្រាតផ្លឹបៗឡើងមកវិញស្លៀករត់ព្រុយរត់ចូលផ្ទះទៅ
មានទៅលេងស្អីទៀតមីអូនអើយអស់ហើយឥឡូវ។

កះចា៎!!ចុះមីងសំរាប់នេះហា៎មីងមានដែលឃើញគេយកមនុស្សទៅសំលាប់ចោលអីទេ??

ខះញ៉ុមមិនដែលឃើញទេ
ដូចញ៉ុមជំរាបពីដើមហ្នឹងថាញ៉ុមទៅបេះផ្លែព្រីងនៅខែវស្សាតែឃើញគេចងមនុស្សនៅគល់ព្រីងហ្នឹង។

កះចា៎!!

ខះគេវះពោះដល់ញ៉ុមស្រែកប្រាប់ម៉េចហ្នឹងហា៎!បានគេដូចថានាំបាសបោរគេហៅក្បាលសរ ក្បាលខ្មៅហ្នឹងគេរកចាប់ខ្ញុំហ្នឹងបាន!!

កះហើយម៉េចបានរួមមខ្លួនពេលហ្នឹង?

ខះតាញ៉ុមហ្នឹងធ្វើកងតូចអំញ៉ុមកងធំ ពូញ៉ុមប្រធានភូមិ ចេះតែលាក់បាំងទៅ!!ហើយបញ្ជូនញ៉ុមទៅនៅពាមជ។

កះកុំអីហ្នឹង??

ខះកុំអីហ្នឹងងាប់១

កះអូយពិបាកណាស់មីងណេះ??

ខះញ៉ុមរត់ចង់ងាប់ហើយរត់ទៅនៅជាមួយអ៊ីញ៉ុម!!ហើយពូញ៉ុមគាត់នៅតែព្រៃ ទៅទៅ គាត់ចេញទៅព្រៃញ៉ុមចេញទៅដែរទៅ!!ដើរឆ្ការព្រៃអ៊ីចឹងទៅហា៎!!
គេអោយកាប់អុស!!កះចា៎!!ខះអោយរោងបាយដុតហ្នឹង!!

កះចា៎!!មីងមានអារម្មណ៍ម៉េចដែរនៅពេលបែកជំនាន់ប៉ុល ពតទៅ?

ខះពេលបែកប៉ុល
ពតខ្ញុំមិនថាអរសប្បាយអីទេខ្ញុំអាក្នុងរោងចក្រហា៎អាក្នុងរោងបាយគេឃើញចានអីល្អៗឆ្នាំងអីល្អៗចេះតែនាំគ្នាជញ្ជូនមកទៅ
យកមកផ្ទះហើយម៉ែញ៉ុមគាត់ស្មោះត្រង់ហ៊ីទុកអោយគេចែកគ្នាវិញ ប្រធានរោងបាយថាហ៊ីម៉ែសុជាអើយយកចានមក
មីសុជាយកមកច្រើនណាស់!!ចែកគ្នា!!ញ៉ុមថាម៉ែយកអោយវិញធ្វើអី??បែកហើយមិនត្រូវអីយកទៅអោយគេវិញ!!
ហ៊ីអោយគេចែកគ្នាវិញ!ហើយមានចែកគ្នាណាប្រធានរោងបាយយកទាំងអស់ហ្នឹង
!!កះហ៊ី!!ខះម៉ែញ៉ុមចាញ់បោកគេដដែលហ្នឹង។

កះមីស្លាប់ច្រើនទេអ្នកភូមិរបស់មីង??

ខ៖ភូមិញុំមអ្នកដែលគេយកទៅសម្លាប់ចោលអត់មានទេ!!មានតែភូមិក្រៅៗគេយកទៅសម្លាប់ចោលញុំមដឹងដែរប៉ុន្តែភូមិញុំមម្នាក់គេអត់បានសម្លាប់ទេ!!បើគេជំលៀសទៅដូចថាអ្នកចេញទៅពីភ្នំពេញអីចឹងគេជំលៀសមកបាត់ដំបង ពោធិ៍សាត់អីហ្នឹងយកគ្នាមក ខេត្តពោធិ៍សាត់បាត់ដំបងហ្នឹងស្លាប់ច្រើន ម៉ែព្រាតកូនកូនព្រាតម៉ែ ៣ ៤ ៥គ្រួសារដែរហើយសុទ្ធតែចិនយួនហាំ!!

ក៖ហ៊ីៗ!!

ខ៖ជំនាន់ហ្នឹងគេស្អប់យួនចិនហ្ហំ!!មក!!

ក៖ហ្នឹងហើយឮល្បីណាស់អីចឹង!!អិចឹងអ្នកមីងឥឡូវ ប្រហែលជាបន្តិចទៀតចូល កូនបន្តិចពេលអ្នកមីងរៀបការ ហាមិនមែនរៀបការទេ ពេលអ្នកមីងស្រលាញ់គ្នាជាមួយគ្នាជាមួយពូហើយបានកូនប៉ុន្មាននាក់ដែរ??

ខ៖ខ្ញុំបានកូន៦នាក់ប៉ុន្តែស្លាប់៤ ភ្លោះ២ដង!!

ក៖ហ្ហំ!!ភ្លោះ២ដង??

ខ៖ចាំ!!ភ្លោះញុំមកើតនៅឆ្នាំ៩៨(១៩៩៨)ហ្នឹងញុំមវះនៅពេទ្យជប៉ុន !!

ក៖ហ៊ីៗ!

ខ៖ប្រុសមួយស្រីមួយស្លាប់ទាំង២។

ក៖មូលហេតុអីមីងពេទ្យគេមានប្រាប់ទេ??

ខ៖កូនកាលហ្នឹងញុំមធ្លាក់ឈាមច្រើនណាស់គេបញ្ជូនមកពេទ្យ កាកបាទក្រហមពេទ្យកាកបាទក្រហមបញ្ជូនញុំមទៅវះនៅពេទ្យជប៉ុន!!ក៖ហ៊ី!!ខ៖ដែលកូនស្រីងាប់ក្នុងពោះទទឹងហាំ!!

ក៖ហ៊ី!!

ខ៖ហើយកូនប្រុសបានអាយុជិត១ឆ្នាំដែរបានស្លាប់។

ក៖បានជិតមួយឆ្នាំថីបានស្លាប់មីង?

ខ៖ឈើមួយយប់ដង្ហក់ក្តៅ ដង្ហក់ក្តៅបានតែមួយយប់ ដង្ហក់យកៗ។

ក៖ហ៊ឺអានិតគ្នាណាស់មីង!!

ខ៖ធំណាស់ល្អទៀត។

ក៖ចាំ!!អ៊ីចឹងកូនទាំងអស់១០នាក់ ហា៦នាក់?

ខ៖ចាំ!!

ក៖៦នាក់ភ្លោះពីរដង៤ !!

ខ៖ហ៊ឺ!!

ក៖ហើយចុះឥឡូវ៣មែនទេ??

ខ៖ចាំ!!

ក៖អ៊ីចឹង៧តើមីង!!

ខ៖ហ៊ឺ!!

ក៖កូន៧សោះហ្នឹង។ឥឡូវឈ្មោះកូនទាំង៧នាក់ហ្នឹងចាំអស់អត់
ថាកូន៧នាក់ហ្នឹងឈ្មោះអីគេខ្លះមីងចាំទេ??

ខ៖អាកូនងាប់ៗទៅហ្នឹង
មី២នាក់ហ្នឹងអត់ដាក់ឈ្មោះទេ!!ដល់កូនអាប្រុសហ្នឹងបើកូនបងហ្នឹងឪវាដាក់ឈ្មោះ ខុន
សេងឌី។

ក៖ចាំ!!

ខ៖ហើយមីនេះ! ខុន ដៅមុនីស៊ីដេត។

ក៖ហ៊ឺវែងទៀត!!

ខ៖ដល់អានេះ អាងាប់ប្រុសហ្នឹង ខេង ខុនខេមរា ដល់មីនេះបញ្ញា។

ក៖ចាំ!!មីអូនឥឡូវអាយុប៉ុន្មានហើយ?

ខ៖១៥ហើយតើ!!

ក៖១៥ឆ្នាំហើយ?

ខ៖ហ្នឹងហើយវាកើត២០០៤ ឥឡូវ២០១៨ហើយ!!

ក៖ចាំ!!

ខ៖១៤។

ក៖ចាំហើយមីអូនគេឈឺអីគេដែរបានគេអត់ធំ?

ខ៖ជំងឺពេលទៅពិនិត្យពេទ្យហ្នឹង កាលវាកើតភ្លាមហ្នឹងដុះសាច់ពោះមុនដំបូងស្តើងដូចស្លឹកស្រូវ យូរៗទៅធំពោងម៉ង!!

ក៖ចំ!!

ខ៖វះកាត់ហើយសាច់២គីឡូ៧ខាំកន្លះ!!

ក៖នៅក្នុងពោះហ្នឹង?

ខ៖ចាំ!!ពេទ្យជប៉ុន។

ក៖ចុះឥឡូវនៅមានដុំទៀតទេ??

ខ៖អត់!!

ក៖តែនៅតែពោង?

ខ៖ថ្លើមធំ។

ក៖ហ្នូ!!តែពេទ្យអត់មានថាអីដែរតើមីងហី??

ខ៖ពេទ្យថាថ្លើមវាធំ ថ្លើមវាតែប៉ុណ្ណឹង ថ្លើមធំចង់ធ្លាក់ហាំ!!

កៈចាំ!!

ខៈហើយមើល មើលអស់ហើយ ដឹងអស់ មើល!!

កៈអីចឹងមានតែតាមជីវិតហ្នឹងហើយមីងណោះ??

ខៈចាំ!!

កៈអីចឹងមីងសំរាប់កូនអ្នកមីងដែលនៅរស់ទាំងប៉ុន្មានមីងមានអោយកូនទៅរៀនខ្លះអត់មីង??

ខៈកូនញ៉ុមបានរៀនទាំងអស់ តែពេលមីបងឈប់រៀនថ្នាក់ទី៨ឈប់អោយរៀន ដោយសារដូចញ៉ុមប្រាប់ពីមុនមកកូននេះវាឈឺពេកអោយមកជួយលក់ដូរ!!

កៈហ៊ឺ!!

ខៈបើសិនកូនញ៉ុមនៅរៀនបានធ្វើអង្គការ។

កៈអ្នកមីងគិតថាម៉េចដែរការសិក្សាមានសារៈសំខាន់ម៉េចដែរសំរាប់ជីវិតបានជាអ្នកមីងអោយកូនទៅរៀនអីចឹងហា៎??

ខៈញ៉ុមនឹកឃើញថាវាសំខាន់ៗហើយ
កាលណាសម័យនេះចេះច្រើនទៅយើងបានការងារស្រួលធ្វើល្អប៉ុន្តែជីវភាពយើងវាតឹងតែងក៏ដកកូនអោយមកជួយលក់ដូរទៅ ខ្វះខាតយើងទាល់ដៃទាល់ជើងហើយជំពាក់លុយគេមិនមែនធម្មតាឯណា ចងការគេមួយខែ៥០រៀល ៥០រៀលមួយខែ២០រៀលអីណោះ!!រត់អត់រួចបានដកកូនយកមកអោយជួយលក់ដូរ!!

កៈហ៊ឺៗ!!

ខៈរកឯណាទាន់បើម្នាក់ឯង!!ខ្លួនទីពឹងខ្លួនមិនដកកូន។

កៈចាំ!!

ខៈដកយកមកលក់ហៀសតាំងពីរៀងតូចហ្នឹង!!

កៈចាំចុះរាល់ថ្ងៃលក់លៀសប៉ុន្មាននាក់សរុបទាំងអស់??

ខះ៣នាក់ហ្នឹង។

កះទាំង៣នាក់ហ្នឹងជាមួយមីងដែរអ៊ីចឹងទៅ??

ខះចា៎!!

កះចា៎!!អ៊ីចឹងអ្នកមីងសំរាប់ជីវិតរបស់អ្នកមីងតាំងពីតូចរហូតដល់ធំការងារអីគេខ្លះដែលអ្នកមីងធ្លាប់ធ្វើខ្លះ??

ខះញ៉ុមតាំងពីតូចមកការងារខ្ញុំមានតែម៉ែញ៉ុមធ្វើស្រែហ្នឹង ហើយនឹងដូចជាធ្វើលូសណ្ដែកសៀងសណ្ដែកបាយហ្នឹងញ៉ុមធ្លាប់ធ្វើតែទាំងអស់ហ្នឹង។

កះចា៎!!

ខះហើយលក់ដូរអីដូចថាញ៉ុមទៅនៅស្រុកគេហ្នឹង កាលមុនញ៉ុមជឹងជ័រជឹកអីចូលយួនដែរ!!

កះជ័រអីគេវិញមីង?

ខះជ័រកៅស៊ូ!តែជឹក!!!

កះអាជ័រកៅស៊ូហ្នឹងមែន??

ខះអើរជ័រវាជ័រក្រែបអីហ្នឹងគេទិញយកមកបង្កក
ជឹករួចបានត្រឹមតែ១០០គីឡូអីហ្នឹងជាមួយប្អូនពៅញ៉ុមដាក់កង់ទៅ បើទូលបាន៥០គីឡូ។

កះហ៊ឺ!!

ខះហើយញ៉ុមធ្វើសណ្ដែកសៀង សណ្ដែកបាយជឹកចូលយួនប៉ុណ្ណឹង។

កះចា៎!!ហើយបានមកផ្លាស់ប្ដូរណោះ??

ខះចា៎!!ចេញពីមេមត់មកវិញឆ្នាំ៨០(១៩៨០)ចូលមកដល់ភ្នំពេញញ៉ុមធ្វើសំណង់។ញ៉ុមធ្វើសំនង់ឆ្អែតអីចឹងទៅ!!ក៏ញ៉ុមទៅណោះខាងណោះស្រុកគេដាក់ក្បូនហ្នូ!!ទន្លេសាប !!

កះចា៎!!

ខះនៅទន្លេសាបទៅមួយខែត្រលប់មកវិញម៉ែញ៉ុមប៉ាញ៉ុមរកមិនឃើញដឹកត្រីងៀតមកពីហ្នឹង បោះអួរឬស្សីហើយក៏ឈប់ទៅ គេប្រកាសកាត់ដេរនៅទឹកថ្លាហ្នឹងហិរោងចក្របើកដំបូងញ៉ុមទៅដេរបានប្រហែលជា២ ៣ថ្ងៃញ៉ុមលែងដេរទៅញ៉ុមដើរធ្វើសំណង់វិញទៅ ដល់ធ្វើជាប់នៅខាងសំណង់ថៃប៊ុនរ៉ុង ធ្វើបានមួយឆ្នាំញ៉ុមឈប់ទៀតទៅ។

កះហើយក៏មកលក់លៀសលក់អីនៅនេះមក??

ខះចាំ!!

កះដូរអ៊ិចឹងទៅ!!ចាំ!!
អ៊ីចឹងអរគុណច្រើនមែនទែនអ្នកមីងសំរាប់ការសំភាសន៍ដែលអ្នកមីងបានរៀបរាប់អំពីជីវិតរបស់អ្នកមីង
អ្នកមីងមានពាក្យអីចង់ផ្តាំផ្ញើទៅកាន់កូនចៅជំនាន់ក្រោយដែលគាត់នឹងស្តាប់ឮសំលេងរបស់មីងខ្លះទៀតអត់?អោយពួកគាត់ដើរលើផ្លូវម៉េចដែរអ៊ីចឹងហាំ??

ខះហ៊ីញ៉ុមមានតែពាក្យអីធំដុំទេ ផ្តាំទៅកូនចៅជំនាន់ក្រោយធ្វើអីអោយតែល្អៗ ប្រឹងរៀនសូត្រអីអោយចេះដឹងទៅរកស៊ីអីតាមអំពើល្អអ៊ីចឹងទៅ
កុំអាដេញអីប្រព្រឹត្តិអារឿងបោកប្រាស់អីគេលួចអីគេក៏វាមិនល្អដែរណាស់!!

កះចាំ!

ខះហើយអារឿងគ្រឿងញៀនអីនេះកុំប្រព្រឹត្តិអោយសោះខ្ញុំស្អប់ជាទីបំផុត។

កះហ្នឹងហើយ។

ខះមានតែប៉ុណ្ណឹងទេអរគុណហើយ។

កះហើយមួយទៀតគឺថាអោយកូនៗកុំក្បត់ប្រពន្ធ!!

ខះហ៊ឺ!!

កះមានតែមួយនឹងមួយមីងណោះ??

ខះហុី!!ហេីយក៏សូមផ្តាំផ្ញើរកូនៗកុំអារឿងរបស់គេឈឺចាប់ណាស់ មិនបានទេ ហេីយសូមផ្តាំផ្ញើរដល់ស្រីដែលស្អាតៗអោយឃើញប្តីគេកុំលេបត្របាក់ពេកវាមិនស្រួលទេក្រែងលោទឹកអាសុីដឡេីងប៉ុណ្ណឹងបានហេីយ។

កះអឺចឹងអរគុណច្រេីនមែនទែនអ្នកមីងសំរាប់ការរៀបរាប់ដ៏ក្បោះក្បាយកូនចៅអ្នកមីងនឹងបានស្តាប់ពុាក្យសំដីអ្នកមីងទាំងអស់ហា៎!!

ខះចា៎!!

កះអរគុណច្រេីនអ្នកមីង។